**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

**Ministry of Environment**

លេខ: ៧៧១ ប.ក ប.ស្ត

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១០

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "ត្រពាំងប្រីយ៍ធំ"
## ភូមិថ្មី ភូមិជាំផល និងភូមិជន្លែង
## ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្នុងដែនជម្រកសត្វព្រៃបឹងពែរ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ-អភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ត្រពាំងប្រីយ៍ធំ"
- តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## សម្រេច

**ប្រការ ១ :** រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "**ត្រពាំងប្រីយ៍ធំ**" ដែលស្ថិតនៅក្នុងភូមិថ្មី ភូមិជាំផល និងភូមិជន្លែង ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ នៃដែនជម្រកសត្វព្រៃបឹងពែរ។

**ប្រការ ២ :** សហគមន៍តំបន់ការពារធម្មជាតិ "**ត្រពាំងប្រីយ៍ធំ**" ក្នុងដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីទំហំ **២៣៣៤ហិចតា** បានកំណត់ទីតាំងព្រំប្រទល់ក្នុងផែនទីដែលមានអាប់ស៊ីស និងកូអ័រដោនេ ដូចខាងក្រោម :

| **ចំណុច** | **អាប់ស៊ីស X** | **កូអ័រដោនេ Y** | **ចំណុច** | **អាប់ស៊ីស X** | **កូអ័រដោនេ Y** |
|---|---|---|---|---|---|
| A | 519427 | 1437001 | F | 517630 | 1441125 |
| B | 517712 | 1436951 | G | 518687 | 1440328 |
| C | 517098 | 1437474 | H | 519484 | 1440246 |
| D | 513058 | 1437616 | I | 520285 | 1439045 |
| E | 512371 | 1440268 | | | |

**ប្រការ ៣ :** ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "**ត្រពាំងប្រីយ៍ធំ**" នៃដែនជម្រកសត្វព្រៃបឹងពែរ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានពាក់ព័ន្ធ កម្រងតំបន់ការពារធម្មជាតិស្ទឹងសែន មន្ទីរបរិស្ថានខេត្តកំពង់ធំ ដែនជម្រកសត្វព្រៃ បឹងពែរ និងសហគមន៍តំបន់ការពារធម្មជាតិ "**ត្រពាំងប្រីយ៍ធំ**" នៃដែនជម្រកសត្វព្រៃបឹងពែរ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទូ

<u>ចម្លងជូន:</u>

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -សាលាខេត្តកំពង់ធំ
- -ឯកសារ-កាលប្បវត្តិ